# ព្រះរាជក្រឹត្យ

នស/រកត/០២១៨/១៧៦

## ស្តីពី

## ការរំសាយដែនជម្រកសត្វព្រៃស្នួល ស្ថិតក្នុងខេត្តក្រចេះ
## និងការរំសាយដែនជម្រកសត្វព្រៃរនាមដូនសំ ស្ថិតក្នុងខេត្តបាត់ដំបង

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ដែលបានកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៣/២៩១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៣
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១១៣/១២៥៣ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៣
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- អនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- បានទទួលយល់សេចក្តីបង្គំទូលថ្វាយរបស់អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១.-**

ត្រូវបានរំសាយដែនជំរកសត្វព្រៃស្នួលដែលមានផ្ទៃដីចំនួន៧៥.០០០ហិកតា ចេញពីព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ដែលបានកំណត់តំបន់ការពារធម្មជាតិ។

**មាត្រា២.-**

ត្រូវបានរំសាយដែនជំរកសត្វព្រៃនាមជូនសំដែលមានផ្ទៃដីចំនួន៣៩.៩៦១ហិកតា ចេញពីព្រះរាជក្រឹត្យ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៣ ដែលបានកែសំរួលផ្ទៃដីតំបន់ដែនជំរកសត្វព្រៃនាមជូនសំ។

**មាត្រា៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៤.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ សុក្រ ១កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស២៥៦១
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចាវស. ១៨០២. ១៧៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**
**ហត្ថលេខា**
**សាយ សំអាល់**

លេខៈ២២២ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃព្រហស្បតិ៍ ៨កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**